

# កំណែរទំរង់គោលនយោបាយវិស័យជលផល
# និងគំរោងថ្មីៗស្ដីពីសហគមន៍នេសាទ
# និងសហគ្រប់គ្រងនេសាទ

ករណីសិក្សា

នៅតំបន់ឡូត៍នេសាទ

ខេត្តសៀមរាប និងខេត្តបាត់ដំបង

នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ និងចងក្រងដោយ :

លោក ម៉ាយ សុធី

២០០២

# កំណែទំរង់គោលនយោបាយវិស័យជលផល និងទស្សនៈថ្មីៗស្តីពី សហគមន៍នេសាទ និងសហគ្រប់គ្រងនេសាទ

**ករណីសិក្សា**

នៅឡូតិ៍នេសាទលេខ ៣, លេខ ៦ លេខ ៣ , ៥ ខេត្តសៀមរាប និងបាត់ដំបង

នៃព្រះរាជណាចក្រកម្ពុជា

**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក ថាយ សុមុនី

**២០០២**

ធនធានជលផលទឹកសាប មានសារៈសំខាន់ណាស់សំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ គោលបំណងនៃការកែទំរង់វិស័យជលផល ដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជននៅតាមជនបទ ព្រមទាំងផ្តល់សិទ្ធិក្នុងការធ្វើនេសាទដល់សហគមន៍មូលដ្ឋាន និងអាចជៀសវាងបាននូវការជះឥទ្ធិពលជាអវិជ្ជមានដល់ប្រពន្ធ័ចិញ្ចឹមជីវិត។ ការរៀបចំសហគមន៍នេសាទ និងសហគ្រប់គ្រង គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិដល់ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព ព្រមទាំងអាចទទួលផលប្រយោជន៍បានសមស្រប។ នេះជាទស្សនៈថ្មីចំពោះបរិបទនយោបាយនៅកម្ពុជា ហើយវានៅមានកង្វះខាត ចំណេះដឹងខ្លះ ព្រមទាំងពុំទាន់បានអនុវត្តទាំងស្រុងនូវរបៀបនេះតាមតំបន់មួយចំនួនទៀត។ ប្រជាជនខ្លះមានការយល់ដឹងពីសហគ្រប់គ្រងនេសាទ ដែលមានសារៈប្រយោជន៍ដល់ជីវភាពរស់នៅ ហើយពួកគាត់មានជំនឿថា បច្ចុប្បន្នពួកគាត់ធ្វើនេសាទតាមរបៀបសហគមន៍នេសាទដោយមានលក្ខន្តិកៈកំណត់យ៉ាងច្បាស់លាស់។ រីឯប្រជាជនមួយចំនួនមានការយល់ថា កំណែទំរង់វិស័យជលផលនេះ នឹងអនុញ្ញាតិអោយមានតែការនេសាទលក្ខណៈគ្រួសារប៉ុណ្ណោះ។ ទស្សនៈទាំងនេះជាកត្តាចំបង ដើម្បីវិភាគបាននូវការអនុវត្តរបៀបសហគ្រប់គ្រងនេសាទ ដែលជាយុទ្ធសាស្ត្រជោគជ័យថ្មីមួយនៃកំណែទំរង់វិស័យជលផលបច្ចុប្បន្ន។

ករណីសិក្សានេះ ត្រូវបានធ្វើឡើងជាចំបងតាមរយៈការសំភាសន៍ជាមួយប្រជានេសាទនៅក្នុងតំបន់ឡូតិ៍លេខ ៣ លេខ ៦ ក្នុងខេត្តសៀមរាប និងឡូតិ៍លេខ ៣ លេខ ៥ ក្នុងខេត្តបាត់ដំបង ហើយព្រមទាំងបានពិគ្រោះយោបល់ខ្លះៗ ជាមួយមន្ត្រីរាជការជលផលខេត្ត បុគ្គលិកគំរោង FAO ខេត្តសៀមរាប និងបុគ្គលិកគំរោង LEUCAENA ផងដែរ។

**ស្រាវជ្រាវ និងចងក្រងដោយ :**

**លោក ម៉ាយ សុមុនី**

មន្ត្រីរាជការនាយកដ្ឋានជលផល

កម្មវិធីអនុបណ្ឌិតផ្នែកគ្រប់គ្រង ស្តីពីធនធានអាហារ និងគ្រប់គ្រងពាណិជ្ជសាស្ត្រកសិកម្ម

វិទ្យាល័យភូមិន្ទកសិកម្ម ប្រទេសអង់គ្លេស

ប្រធានស្តីទី ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល

**អ្នកចូលរួមសំខាន់**

**លោក ណៅ ធួក**

ប្រធាននាយកដ្ឋានជលផល

ក្រុមគំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

លោក ប៉ាទ្រីក អែវ៉ាន និងបុគ្គលិកអង្គការហ្វាវ ខេត្តសៀមរាប

សមាជិកសហគមន៍នៃឡូត៍នេសាទលេខ ៣ . លេខ ៦ និងលេខ ៣. ៥ ខេត្តសៀមរាប និងបាត់ដំបង

បុគ្គលិកគំរោង លូស៊ីណា នៃខេត្តបាត់ដំបង

លោក នីកូឡា វ៉ាន់ស្សាលីន ទីប្រឹក្សាបច្ចេកទេស គ្រោងការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា

**ទីប្រឹក្សា**

**លោក ឌុចឺ ទាហ្វ៊ីន**

ទីប្រឹក្សាគំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

**កែសំរួលដោយ:**

**លោក កែវចិន វិចី**

**ឧបត្ថម្ភដោយ**

-ការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាបរបស់អង្គការហ្វាវ ខេត្តសៀមរាប (FAO)

-គំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៃអង្គការ WWF

-មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍ (IDRC)

-អង្គការអុកស្វាមអាមេរិកាំង

-មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ (RECOFTC)

## អារម្ភកថា

## ដំណើរការករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តន៍ថ្មីមួយចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះ បង្កើតចេញជាសមាសភាគសំខាន់មួយនៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត ។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើងនៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០ នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញ គ្រឹះសំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និងចងក្រងឯកសារ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាលករណីសិក្សាមួយទៀតបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគីរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ ដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហាព្រៃឈើដែលបានបង្កើតឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេត្តរតនៈគីរី និងមណ្ឌលគីរី) តំបន់ទំនាបកណ្តាល (ខេត្តពោធិសាត់ និងកំពង់ឆ្នាំង) តំបន់ទន្លេមេគង្គ ឬទន្លេសាប (ខេត្តស្ទឹងត្រែង និងសៀមរាប) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងក្រុងកំពង់សោម)។

តាមករណីជាច្រើន សេចក្តីព្រាងលើកទី ១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធ ចម្រុះដោយចាប់ពី ខែ មករា ដល់ ខែ មេសា ឆ្នាំ ២០០២ ។ សេចក្តីព្រាងលើកទី ២ ត្រូវបានលើយកមកបង្ហាញដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុង ខែ ឧសភា ឆ្នាំ២០០២។ នៅពេលនោះ ករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួលដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។ អ្នកសម្របសម្រួលគំរោងនៅតាមមូលដ្ឋាន ដើរតួនាទីឈានមុខក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ។ អ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពត៌មាន ការបកប្រែ និងការកែសម្រួល។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើន

ដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា ។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវបានគេចែករំលែកផងដែរ នៅតាមវេទិកានានាដូចជា សិក្ខាសាលាថ្នាក់ជាតិស្តីពី CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២។ គេរំពឹងទុកថាលទ្ធផលនេះនឹងត្រូវ បានប្រើប្រាស់ ដើម្បីជាពត៌មានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា។

## មាតិកាអត្ថបទ

### ធ្វើឲ្យអនុវត្តសហគ្រប់គ្រងនេសាទតាមរយៈកំណែទំរង់គោលនយោបាយវិស័យជលផល

### ការវិភាគទស្សនៈរបស់សហគមន៍មូលដ្ឋាន និងថាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់


១.សេចក្ដីផ្ដើម..........៧

២.បញ្ហាសំខាន់ៗ ដែលបណ្ដាលឱ្យមានការកែទំរង់ការគ្រប់គ្រងជលផលទឹកសាប..........៨

៣.ទស្សនៈរបស់ប្រជានេសាទចំពោះការកែទំរង់ការគ្រប់គ្រងវិស័យជលផល និងសហគ្រប់គ្រងនៃវិស័យជលផល..........១០

៤.សហគ្រប់គ្រងនៃធនធានជលផល..........១១

តារាងទី១: ភាពខុសគ្នារវាងសហគ្រប់គ្រង និងការគ្រប់គ្រងធនធានផ្អែកលើសហគមន៍..........១៣

៥.ការភ័ន្តច្រឡំរវាងក្រុមសាមគ្គីនេសាទ រឺក្រុមសហករ និងសហគ្រប់គ្រងសហគមន៍នេសាទ..........១៤

៦.ការផ្សព្វផ្សាយពត៌មានមិនច្បាស់លាស់នៃសហគ្រប់គ្រង តាមរយៈបណ្ដាញការផ្សព្វផ្សាយ..........១៥

៧.កំរិតយល់ដឹងរបស់សហគមន៍ក្នុងតំបន់..........១៥

៨.ច្បាប់ជលផលចាស់ដែលហួសសម័យ..........១៦

៩.ការជំពាក់ទាក់ទិនទៅនឹងការបំផ្លាស់ប្ដូរសង្គមនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន..........១៧

១០.សេចក្ដីសន្និដ្ឋាន..........១៨

១១.អនុសាសន៍..........១៨

ឯកសារយោង: ..........១៩

ប្រវត្តិគំរោងករណីសិក្សា "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ..........២៣

តារាងឧបសម្ព័ន្ធទី ១ ផលនេសាទចាប់បានប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ ១៩៩៤ ដល់ ១៩៩៧

តារាងឧបសម្ព័ន្ធទី ២: ផែនទីបង្ហាញពីទីតាំងសិក្សា នៅឡូត៍លេខ ៣ និង ៦ ខេត្តសៀមរាប

តារាងឧបសម្ព័ន្ធទី ៣: ផែនទីបង្ហាញពីតំបន់ធ្វើករណីសិក្សានៅឡូលេខ៩ ខេត្តបាត់ដំបង

តារាងឧបសម្ព័ន្ធទី ៤: តំបន់ឡូត៍នេសាទក្រោយពេលកែទំរង់វិស័យជលផល

## ដើម្បីអនុវត្តសហគ្រប់គ្រងនេសាទតាមរយៈកំណែទំរង់គោលនយោបាយវិស័យជលផល ការវិភាគទស្សនៈរបស់សហគមន៍មូលដ្ឋាន គឺជាយុទ្ធសាស្ត្រមួយដ៏មានសារៈសំខាន់

### ១.សេចក្តីផ្តើម

កម្ពុជាជាប្រទេសមួយដែលសំបូរដោយធនធានធម្មជាតិ។ ក្នុងចំណោមធនធានទាំងនោះ ត្រីទឹកសាបជាធនធានសំខាន់មួយដែលផ្តល់នូវសុវត្ថិភាពស្បៀងអាហារ និងប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋកម្ពុជា។ ទិន្នន័យនៃផលទឹកសាបរបស់នាយកដ្ឋានជលផលដែលមានពីមុន គឺមានតែ ៧៥.០០០តោនប៉ុណ្ណោះ តែយោងតាមរបាយណ៍របស់លោក វ៉ាន់ ស្សាលីន ឆ្នាំ១៩៩៨ ការប៉ាន់ស្មានផលចាប់ត្រីទឹកសាបប្រចាំឆ្នាំដែលជាទិន្នន័យថ្មី និងគួរឱ្យជឿជាងនេះទៅទៀត គឺមានពី ២៩០.០០០-៤៥០.០០០តោន ។ យោងតាមទិន្នន័យថ្មីនេះ ប្រទេសកម្ពុជា ជាប្រទេសទីបួនដែលសំបូរត្រីទឹកសាបនៅលើពិភពលោក (តាមរបាយការណ៍របស់លោក ឌីហ្គេន និងសហការី ឆ្នាំ ២០០០)។ ផលិតផលនេះ បានមកពីធ្វើអាជីវកម្មជាលក្ខណៈឧស្សាហកម្ម (ឡូតិ៍នេសាទ[២] និងដាយ[៣]) សិប្បកម្ម[៤] នេសាទគ្រួសារ[៥] និងក្នុងស្រែ[៦] (សូមមើលតារាងឧបសម្ព័ន្ធទី១)។

ជាទូទៅ ការគ្រប់គ្រងធនធានត្រីទឹកសាបនៅប្រទេសកម្ពុជា ទទួលឥទ្ធិពលពីនយោបាយ និងរបបសង្គមនីមួយៗនាពេលអតីត និងបច្ចុប្បន្ន។ ប្រពន្ធ័នៃការគ្រប់គ្រងនីមួយៗ ផ្តល់នូវលទ្ធផលទាំងវិជ្ជមាន និងអវិជ្ជមានទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទ និងស្ថានភាពធនធានជលផល។ ចាប់តាំងពីរបបប៉ុលពតត្រូវបានបញ្ចប់ (១៩៧៥-១៩៧៩) រហូតមកដល់ពេលបច្ចុប្បន្ននេះ ធនធានជលផលត្រូវបានគ្រប់គ្រង និងធ្វើអាជីវកម្មតាមរបៀបផ្សេងៗគ្នា ដែលអាចសង្ខេបបានដូចមានខាងក្រោម:

---

១- ឡូតិ៍នេសាទត្រូវបានដាក់ឱ្យដេញថ្លៃ ដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងតំបន់ដែលសំបូរសំរាប់ការធ្វើអាជីវកម្មទាំងស្រុងដែលមានដើមកំណើតពីឆ្នាំមុន ។ នេះជាវិធានការដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតប្រាក់ចំណូលពីការជួលធនធានជលផល (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

២- ដាយជាប្រភេទមងយ៉ាង វី ដែលគេដាក់នៅមួយកន្លែងក្នុងទឹក ដើម្បីចាប់ត្រីដែលធ្វើចរាចរណ៍មកក្រោមខ្សែទឹក (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ ២០០០) ។

៣- នេសាទជាលក្ខណៈសិប្បកម្ម ។ នៅប្រទេសកម្ពុជា នេសាទសិប្បកម្មដែលស្របច្បាប់លុះត្រាតែមានលិខិតអនុញ្ញាតជាមុន ។ វាត្រូវបានអនុញ្ញាតឱ្យប្រើទៅតាមប្រភេទនិងទំហំរបស់ឧបករណ៍នេសាទដែល ធំជាងនេសាទគ្រួសារ (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

4&5- នេសាទជាលក្ខណៈគ្រួសារនិងនេសាទក្នុងស្រែ បានបើកសិទ្ធិឱ្យនេសាទដោយមិនចាំបាច់មានលិខិតអនុញ្ញាតទេ ។ ប៉ុន្តែឧបករណ៍នេសាទត្រូវបានបែងចែកឱ្យប្រើទៅតាមទំហំដែលមានការកំណត់ច្បាស់លាស់ ។ ការធ្វើនេសាទតាមឡូតិ៍នេសាទត្រូវបានបិទនៅរដូវបិទនេសាទ (ពីខែមិថុនា ដល់ ខែ កញ្ញា) (តាមរបាយការណ៍របស់លោក វ៉ាន់ ស្សាលីន និង សហការី ឆ្នាំ២០០០) ។

១៩៧៩-៨២: តំបន់នេសាទជាលក្ខណៈសាធារណៈ

១៩៨២-៨៩: ក្រុមសាមគ្គី

១៩៨៩-៩៨: ឡូត៍នេសាទលក់ដោយដាក់ឱ្យដេញថ្លៃ

១៩៩៨-២០០០: ឡូត៍នេសាទដែលមានការដាក់ជួលបន្ត និងឡូត៍ស្រាវជ្រាវ

២០០១: ដំណាក់ការកែទំរង់ប្រពន្ធ័គ្រប់គ្រងវិស័យជលផល

តាមរបាយណ៏របស់លោក ឌីហ្គែន និងលោក ឈៅ ធូក ឆ្នាំ២០០០ បានផ្តល់នូវការបកស្រាយលំអិតមួយនៃការប្រើប្រាស់ធនធានជលផល និងស្ថានភាពការចិញ្ចឹមជីវិតរបស់ប្រជានេសាទចាប់តាំងពីរបបខ្មែរក្រហមមកទល់ឆ្នាំ ១៩៩៩-២០០០។ សំរាប់ការបកស្រាយលំអិត ស្តីពីការជះឥទ្ធិពលនៃប្រពន្ធ័គ្រប់គ្រងផ្សេងៗ ទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទនៅឡូត៍លេខ ៣ ខេត្តសៀមរាប សូមមើលរបាយការណ៏នៃករណីសិក្សាលេខ៤ ស្តីពីការផ្លាស់ប្តូរបទពិសោធន៏ពីគ្នាទៅវិញទៅមករបស់កម្មវិធីសហគមន៏ គ្រប់គ្រងធនធានធម្មជាតិ (CBNRM): ជាករណីសិក្សាតគ្នាមួយរបស់កម្មវិធីសហគមន៏គ្រប់គ្រងធនធានធម្មជាតិ (CBNRM) ស្តីពីបឹងទន្លេសាប។

នៅក្នុងអត្ថបទនេះ នឹងចាប់ផ្តើមពិភាក្សាដោយសង្ខេបទៅលើបញ្ហាសំខាន់ៗដែលជាមូលហេតុឱ្យមានការកែទំរង់ប្រពន្ធ័គ្រប់គ្រងវិស័យជលផល។ ការវិភាគទៅលើទស្សនៈរបស់ប្រជានេសាទ ស្តីអំពីសហគ្រប់គ្រង គឺជាចំណុចផ្តោតយ៉ាងសំខាន់ នៅក្នុងអត្ថបទនេះ។

## ២.បញ្ហាសំខាន់ៗ ដែលបណ្តាលឱ្យមានការកែទំរង់ការគ្រប់គ្រងជលផលទឹកសាប

ធនធានជលផលត្រូវបានគេធ្វើអាជីវកម្មយ៉ាងច្រើនលើសលប់ក្នុងកំឡុងរយៈពេលពីរបីឆ្នាំមុននេះ ដោយសារតែការលើកទឹកចិត្តការអភិវឌ្ឍន៏សេដ្ឋកិច្ចបែបទីផ្សារសេរី និងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពទូទាំងប្រទេស។ ដោយសារតែឧស្សាហកម្មព្រៃឈើដែលបានផ្តល់កំរៃច្រើនត្រូវបានបញ្ឈប់ ធ្វើឱ្យគេបង្វែរទិសដៅមកវិនិយោគទុនផ្នែកឧស្សាហកម្មជលផលវិញ។

ម្ចាស់ឡូត៍នេសាទបានពង្រីកតំបន់ឡូត៍នេសាទ ហើយបានកៀបសង្កត់ទៅលើអ្នកនេសាទគ្រួសារតូចតាចកាន់តែច្រើនឡើងក្នុងតំបន់។ ជាងនេះទៀត មានការជ្រៀតជ្រែកពីអ្នកមានអំណាចទាំងនេះ ក្នុងការត្រួតត្រាដែននេសាទផងដែរ។

របាយការណ៏របស់លោកហ្គាម ឆ្នាំ២០០០ បានកត់ត្រាទុកនូវពត៌មានដែលគួរឱ្យជឿបានពីអ្នកនិពន្ធជាច្រើន ស្តីពីបញ្ហាបញ្ហានូទៅក្នុងកំឡុងពេលឆ្នាំ ១៩៩៨-២០០០។ ក្នុងនោះ បញ្ហាសំខាន់ៗ រួមមាន:

-ការផ្តោតលើការប្រមូលប្រាក់ចំណូលពីការធ្វើឡូត៍នេសាទ ជាជាងការគ្រប់គ្រងធនធានជលផលដោយមាន និរន្តភាព រឺក៏អភិវឌ្ឍន៏ជនបទដែលមានសមធម៌។

- ទំនាស់រវាងការរានដីព្រៃលិចទឹកធ្វើកសិកម្ម និងការធ្វើអភិរក្ស ។

-ការកើនឡើងនូវអ្នកស្វែងរកផលប្រយោជន៏ពីការធ្វើនេសាទក្នុងរយៈពេលខ្លី (ដូចជា ប្រជាជនក្នុងស្រុក និងក្រៅស្រុក អ្នកនេសាទ ទាហាន និងប៉ូលីស)។

- ភាពតានតឹង និងទំនាស់រវាងអ្នកស្រុក និងម្ចាស់ឡូត៍ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។